# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៨ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ
- យោងតាមសំណូមពរ និងការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការ ដើម្បីរៀបចំបុណ្យសពឯកឧត្តម តុល ឡោះ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | អ៊ឹម | សិទ្ធី | សហប្រធាន |
| ២- | ឯកឧត្តម | ប៉ុក | ថន | សហប្រធាន |
| ៣- | ឯកឧត្តម | ប៊ុន | សុខ | អនុប្រធាន |
| ៤- | ឯកឧត្តម | ហែម | សំកុល | អនុប្រធាន |
| ៥- | ឯកឧត្តម | ឆយ | អួន | សមាជិក |
| ៦- | ឯកឧត្តម | កើ | ណៃលាង | សមាជិក |
| ៧- | លោក | ជា | អៀង | សមាជិក |
| ៨- | លោក | លី | សន្និក | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

- ទទួលបន្ទុករៀបចំបុណ្យសពឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អោយបានល្អប្រសើរ ស្របតាមប្រពៃណី សាសនា និងអោយបានសក្តិសមនឹងកិត្តិយសរបស់សព ដោយសហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ ។

- ដោះស្រាយថវិកាសំរាប់បំរើការងាររៀបចំពិធីបុណ្យសព ។
- សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធានគណៈកម្មការ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ សហប្រធានគណៈកម្មការរៀបចំបុណ្យសព ឯកឧត្តម តុល ឡោះ និងសមាសភាពគណៈកម្មការដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤*

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*